**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣៦៤៤ ព.ណ.ក.ស.ប

ថ្ងៃ ២៧ ខែ ឆ្នាំ ព.ស.២៥......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០.....

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ហ្ស៊ីដាខ ខាយសាន ម៉ាស៊ីនើរី (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ:** លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក 志高掘进 ZEGA លើផលិតផលម៉ាស៊ីន និងឧបករណ៍ម៉ាស៊ីនដំណើរការដោយថាមពល របស់ក្រុមហ៊ុន **ហ្ស៊ីដាខ ខាយសាន ម៉ាស៊ីនើរី (ខេមបូឌា) ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ហ្ស៊ីដាខ ខាយសាន ម៉ាស៊ីនើរី (ខេមបូឌា) ឯ.ក** ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៨០៤១២/២១ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ជូនលោក/លោកស្រីប្រធានជ្រាបថា តាមរយៈការចុះបញ្ជីម៉ាកដែលមានលេខចុះបញ្ជី KH/៨០៤១២/២១ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនរបស់លោក/លោកស្រីបានទទួលសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ ក្នុងការផលិត នាំចូល ចែកចាយ ដាក់តាំង ឬផ្សព្វផ្សាយ ចំពោះទំនិញដែលជាកម្មវត្ថុនៃការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាស្វ័យប្រវត្តិ ដូចមានចែងក្នុងមាត្រា ៣ និងមាត្រា ១១ នៃច្បាប់ដែលបានយោងខាងលើនេះ។

លិខិតបញ្ជាក់នេះ មានសុពលភាព ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវអស់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ក្នុងករណីដែលការចុះបញ្ជីម៉ាកត្រូវបានបាត់បង់សុពលភាពដោយប្រការណាមួយនោះ។

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រុជា**

***ចម្លងជូន:***
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ- កាលប្បវត្តិ*